ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការរៀបចំកម្មវិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣១ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០១៧

ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣១ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០១៧ ក្រោមប្រធានបទ "ដើម្បីសន្តិភាព ការងារ មុខរបរ និងអភិវឌ្ឍន៍" ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំនូវវេទិកាពិភាក្សាអំពីទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជា ដោយមានការចូលរួមយ៉ាងទូលំទូលាយពីគ្រប់តំណាងភាគីពាក់ព័ន្ធក្នុងវិស័យការងារដូចជា តំណាងក្រសួង-ស្ថាប័នរដ្ឋពាក់ព័ន្ធ អង្គការវិជ្ជាជីវៈ កម្មករ និយោជិត និយោជក អង្គការអន្តរជាតិខាងការងារ (ILO) និងអង្គការសង្គមស៊ីវិល ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយរួមគ្នាលើបញ្ហាកង្វល់ ឬសំណូមពរជាអាទិភាព របស់បងប្អូនកម្មករនិយោជិត និងនិយោជក។ ទន្ទឹមនឹងនេះ ដើម្បីបង្កើតឱកាសសប្បាយរីករាយដល់បងប្អូនកម្មករនិយោជិត ដែលកំពុងបម្រើការងារក្នុងវិស័យឧស្សាហកម្មផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត ក្រសួងក៏បានសហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សហភាពសហព័ន្ធយុវជនកម្ពុជា (សសយក) អង្គការវិជ្ជាជីវៈ ស្ថានីយទូរទស្សន៍អ៊ីធីវី (ETV) និងដៃគូពាក់ព័ន្ធនានា រៀបចំ "**កម្មវិធីសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៧**" នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧ ផងដែរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និយោជក អង្គការជាតិនិងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៧

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩